# ថ្នាំបង្ការរោគ

## ចាក់ថ្នាំបង្ការ ដើម្បីឲ្យអ្នកនៅមានសុខភាពល្អ

**ថ្នាំបង្ការរោគ គឺជាការចាក់ថ្នាំបង្ការដែលរក្សាអ្នកកុំឲ្យឈឺថ្កាត់**

## តើហេតុអ្វីបានជាខ្ញុំត្រូវការ ថ្នាំបង្ការរោគ?

មានជំងឺជាច្រើននៅក្នុងសហរដ្ឋអាមេរិក ដែលកាលពីមុនបានធ្វើឲ្យមនុស្សឈឺថ្កាត់ខ្លាំងណាស់ កំពុងតែសាបសូន្យ។ មូលហេតុដ៏ចំបងមួយ គឺការប្រើនូវថ្នាំបង្ការរោគ។ ថ្នាំបង្ការរោគជួយការពារជំងឺនានា ដែលអាចឆ្លងពីមនុស្សម្នាក់ ទៅម្នាក់ទៀត។ នៅពេលអ្នកចាក់ថ្នាំបង្ការដែលអ្នកត្រូវការ អ្នកការពារខ្លួនអ្នក និងមនុស្សជាទីស្រឡាញ់របស់អ្នកកុំឲ្យឈឺថ្កាត់។

## តើថ្នាំបង្ការរោគមានប្រសិទ្ធិភាពយ៉ាងណា?

ថ្នាំបង្ការរោគ គឺបានផលិតចេញពីវីរុសដូចគ្នា (ក៏ហៅថា មេរោគ ដែរ) ដែលបណ្តាលឲ្យមានជំងឺ។ មេរោគត្រូវបានប្រើដើម្បីផលិតថ្នាំបង្ការរោគ គឺជាបាន "ងាប់" ឬខ្សោយ។ វានឹងមិនធ្វើឲ្យអ្នកឈឺថ្កាត់ទេ។ ផ្ទុយទៅវិញ វានឹងជួយខ្លួនប្រាណរបស់អ្នក ប្រយុទ្ធនឹងមេរោគ និងជំងឺនានាដែលវាបណ្តាលឲ្យឈឺថ្កាត់។

## តើអ្នកណាត្រូវការ ថ្នាំបង្ការរោគ?



## តើមានប្រតិកម្មបន្ទាប់បន្សំឬទេ?

មនុស្សខ្លះមានប្រតិកម្មបន្ទាប់បន្សំ បន្ទាប់ពីគេបានចាក់ថ្នាំបង្ការ។ ប្រតិកម្មទាំងនេះនឹងលែងមានទៀត ក្នុងពេលមួយ ឬពីរថ្ងៃ។



ឈឺ/ទ្បើងក្រហម    កន្ទួលបន្តិចបន្តួច    គ្រុនស្រាល

មនុស្សខ្លះកម្រមានប្រតិកម្មបន្ទាប់បន្សំអាក្រក់ បន្ទាប់ពីគេបានចាក់ថ្នាំបង្ការ។ ភាគច្រើននៃពេល វានឹងកើតឡើងក្នុងពេលពីរបីនាទី ឬពីរបីម៉ោងបន្ទាប់ពីបានចាក់ថ្នាំបង្ការ។



ពិបាកដកដង្ហើម    វិលមុខ    កន្ទួល/រមាស់    ហើមបំពង់ក

## តើខ្ញុំត្រូវការ ថ្នាំបង្ការរោគប្រភេទអ្វី?

តារាងនៅម្ខាងទៀត បង្ហាញថ្នាំចាក់បង្ការប្រភេទអ្វីដែលមនុស្សពេញវ័យ និងក្មេងៗត្រូវការ។ មនុស្សពេញវ័យមិនបាច់ចាក់ថ្នាំបង្ការទាំង អស់ទេ ក្នុងខណៈក្មេងៗអាចនឹងត្រូវការថ្នាំចាក់បង្ការច្រើនជាង។
សូមពិគ្រោះជាមួយវេជ្ជបណ្ឌិតរបស់អ្នក ដើម្បីសាកសួរថាអ្នកត្រូវការថ្នាំចាក់បង្ការណាមួយ។

**ឈ្មោះវេជ្ជបណ្ឌិតខ្ញុំ:**

______________________

**លេខទូរស័ព្ទវេជ្ជបណ្ឌិតខ្ញុំ:**

______________________

**សំរាប់ព័ត៌មានបន្ថែម សូមទៅមើល: www.vaccines.gov**

Translated by: Sary Hem


Copyright © 2015, MAGNUS, Walnut, CA

# ចាក់ថ្នាំបង្ការ ដើម្បីឲ្យអ្នកនៅមានសុខភាពល្អ

## ទៅជួបវេជ្ជបណ្ឌិតរបស់អ្នក សំរាប់ការពិនិត្យសុខភាពគ្រប់ និងចាក់ថ្នាំបង្ការថ្មី ដែលអ្នកត្រូវការ។

ការចាក់ថ្នាំបង្ការដែលបានគូសនៅខាងក្រោម គឺត្រូវការសំរាប់:____________________ (ឈ្មោះ) ________________ (អាយុ)

ការជួបពិគ្រោះរបស់អ្នកបន្ទាប់ទៀតគឺ: ________ (កាលបរិច្ឆេទ) ________________ (ពេលវេលា) (ព្រឹក/ល្ងាច) ________________ (ខែថ្ងៃឆ្នាំកំណើត)

| ថ្នាំបង្ការអ្នកត្រូវការ | តើវាហៅជាអ្វី? | តើអ្នកណាត្រូវការវា? | | | តើថ្នាំបង្ការជួយការពារជំងឺអ្វី? | តើជំងឺបណ្ដាលឲ្យមានអ្វី? |
|---|---|---|---|---|---|---|
| | | តែក្មេងៗ* | ក្មេងៗ និងមនុស្សពេញវ័យ | តែមនុស្សពេញវ័យ | | |
| ☐ | DTaP ឬ Td/Tdap | | X | | ខាន់ស្លាក់ | គ្រុន ឈឺបំពង់ក និងស្រៀវស្រាញ |
| | | | | | តេតាណុស | ឈឺចុកអួលសាច់ដុំខ្លាំង និងពិបាកដកដង្ហើម ឬពិបាកលេប |
| | | | | | ក្អកខុងៗ | ក្អក់ធ្ងន់ធ្ងរ និងពិបាកដកដង្ហើម បរិភោគ និងពិបាកពិសារទឹក |
| ☐ | ផ្តាយសាយធំ | | X | | ផ្តាយសាយធំ | ការរលាកច្រមុះ បំពង់ក និងសួត |
| ☐ | HepA | | X | | រលាកថ្លើមប្រភេទ A | ប្រភេទនៃជំងឺថ្លើម |
| ☐ | HepB | | X | | រលាកថ្លើមប្រភេទ B | ប្រភេទនៃជំងឺថ្លើម |
| ☐ | Hib | | X | | ហេម៉ូហ្វីលុស ប្រភេទប៊ី | ការរលាកនៃទ្រនាប់នៅជុំវិញខួរក្បាល និងទ្រនង់ខួរឆ្អឹងខ្នង |
| ☐ | HPV | | X | | មហារីក-កស្បូន | ប្រភេទនៃជំងឺមហារីករបស់ស្ត្រី |
| | | | | | ឬសអង្គជាត | ប្រភេទនៃជំងឺដែលអាចបានឆ្លងតាមរយៈ ការសេពសន្ថវៈ |
| ☐ | IPV | X | | | ស្វិតសាច់ដុំ | ខ្លួនប្រាណមិនអាចកំរើកបាន ឬនៅពេលខ្លះ មិនអាចទាំងដកដង្ហើមបានផង |
| ☐ | MCV4 | | X | | រលាកស្រោមខួរក្បាល | ការរលាកនៃទ្រនាប់នៅជុំវិញខួរក្បាល និងទ្រនង់ខួរឆ្អឹងខ្នង |
| ☐ | MMR | | X | | កញ្ជ្រឹល | គ្រុន កន្ទួល ហៀរសំបោរ និងក្អក |
| | | | | | សាលាទែន | គ្រុន ឈឺក្បាល និងហើមផ្អែកនៃមាត់ ដែលផលិតទឹកមាត់ |
| | | | | | ស្អូច | គ្រុន ហើមក្រពេញ និងកន្ទួល |
| ☐ | PCV | | X | | ហើមសួត | ការរលាកនូវសួត |
| ☐ | RV | X | | | រ៉ូតាវីរុស | គ្រុន ក្អួតចង្អោរ និងរាគអាចម៍ |
| ☐ | អុតតូច | | | | អុតស្វាយ | កន្ទួលរមាស់នៅពេញខ្លួនប្រាណ |
| ☐ | អុតធំ | | | X | មហាអុត | កន្ទួល និងពងបែក ឈឺខ្លាំងណាស់ |

** ក្មេងៗអាយុ 0 ទៅ 18 ឆ្នាំ*

**រក្សាអ្នក និងមនុស្សជាទីស្រឡាញ់របស់អ្នក ឲ្យមានសុខភាពល្អ។ ចូរចាក់ថ្នាំការពារខ្លួនអ្នក។**

MAGNUS

www.magnuscorp.com/ffs/vaccines

Copyright © 2015, MAGNUS, Walnut, CA